ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មករា ២០០៨ / January 2008

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភឹម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ និង យេន សុផានី**

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទីបី ២០០៧ គំរោងអនុម័តក្នុងវិស័យសេវាកម្មកើន ៧ដង ធៀបនឹងតំលៃរបស់វាក្នុងត្រីមាសមុន ដល់ ៩៥៧,៧លានដុល្លារ។ គំរោងអនុម័តសេវាសណ្ឋាគារកើនពី សូន្យ រហូតដល់ ២,៩លានដុល្លារ និងគំរោងអនុម័តសេវាទេសចរណ៍កើន ១២ដង ដល់ ៦៥០,៩លានដុល្លារ ធៀបនឹងតំលៃនៅត្រីមាសមុន។

In the third quarter of 2007, service sector approvals rose approximately to seven times their value in the previous quarter to USD957.7 m. Hotel services approvals increased from nil to USD2.9 m and tourism services rose to 12 times the previous value to USD650.9 m.

**Service Sector Approvals**
2005 Q1–2007 Q3




*Including expansion projects.*
Source: Council for the Development of Cambodia

នៅខែតុលា ២០០៧ ភ្ញៀវបរទេសមកប្រទេសកម្ពុជា កើន ១៨% ធៀបនឹងខែមុនដល់ ១៦០.២៣៥នាក់។ ភ្ញៀវធ្វើដំណើរតាមផ្លូវគោក កើន ១១% ដល់ ៥៤.០១៩នាក់ និង ភ្ញៀវធ្វើដំណើរតាមផ្លូវទឹក កើន ២៦% ដល់ ៣០២០នាក់។ ភ្ញៀវមកដល់តាមផ្លូវអាកាសមានសរុប ១០៣.១៩៦ នាក់ រឺកើនឡើង ២០%។ ក្នុងនេះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានទទួល ៤៣% និង អាកាសយានដ្ឋានសៀមរាប បានទទួល ៥៧%។ ភ្ញៀវបរទេសមកវិស្សមកាលមាន ៨០% នៃភ្ញៀវសរុប រឺកើន ២១% ធៀបនឹងខែមុន។

Foreign visitors to Cambodia increased by 18 percent from the preceding month to 160,235 in October 2007. Visitors by land rose 11 percent to 54,019 and by water increased 26 percent to 3020. Arrivals by air totalled 103,196, a rise of 20 percent. Of this, Phnom Penh international airport received 43 percent and Siem Reap airport 57 percent. Visitors on holiday were 80 percent of total arrivals and increased by 21 percent from a month earlier.

**Cambodia: Foreign Visitor Arrivals**
August 2006–October 2007




Source: Ministry of Tourism

នៅខែសីហា ២០០៧ គំរោងអនុម័តការសាងសង់នៅភ្នំពេញ ថយចុះ ៣,៨% ធៀបនឹងខែមុន មកត្រឹម ៨៤,៤លានដុល្លារ។ ការអនុមតិសំណង់ភូមិគ្រឹះ និងផ្ទះ ថយចុះ ៩៧% មកត្រឹម ០,៥លានដុល្លារ រីឯការអនុមតិសំណង់ផ្ទះល្វែង កើនមួយជាពីរដល់ ៧៦,៣លានដុល្លារ។ ទោះបីយ៉ាងណាក៏ដោយ គំរោងអនុម័តការសាងសង់សរុប កើនច្រើនជាងពីរដង ធៀបនឹងតំលៃនៅក្នុងខែដូចគ្នា ឆ្នាំ២០០៦។

In August 2007, Phnom Penh construction approvals dropped by 3.8 percent from the previous month to USD84.4 m. Villa and house approvals decreased by 97 percent to USD0.5 m, while flat approvals doubled to USD76.3 m. Total construction approvals, however, increased to more than two times the value in the same month in 2006.

**Phnom Penh: Value of Construction Approvals**
June 2006–August 2007




Data were revised from June 2006 to August 2007
Source: NBC's *Economic & Monetary Statistics Review*

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ

# Consumer Prices and Interest Rates on Bank Deposits

នៅខែវិច្ឆិកា ២០០៧ ថ្លៃទំនិញទូទៅ ថយចុះ ០,២% ធៀបនឹងខែមុន។ តំលៃអាហារ ភេសជ្ជៈ និងថ្នាំជក់ ថយចុះ ១,៤% រីឯថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ៤,៩%។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ថ្លៃទំនិញទូទៅកើន ៩,៥% ដែលក្នុងនោះថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់កើន ១៧,៧% និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ១១,២%។

In November 2007, overall prices declined by 0.2 percent from the preceding month. Food, beverage and tobacco prices dropped by 1.4 percent, while transportation and communication costs increased 4.9 percent. Compared to the same month in 2006, all item prices increased by 9.5 percent; food, beverages and tobacco rose by 17.7 percent, and transportation and communications rose by 11.2 percent.

**Phnom Penh: Consumer Price Index**
(July–December 2000=100)
September 2006–November 2007




Source: National Institute of Statistics

នៅខែធ្នូ ថ្លៃសាំង និងម៉ាស៊ូត នៅថេរមិនប្រែប្រួល។ សាំងលក់ក្នុងតំលៃ ៤៤៦០រៀល/លីត្រ និង ម៉ាស៊ូតលក់ក្នុងតំលៃ ៣៨០០រៀល/លីត្រ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ថ្លៃសាំង កើន ១២ % និង ថ្លៃម៉ាស៊ូត កើន ១៧%។

In December, both gasoline and diesel prices were stable. Gasoline sold at 4460 riels/ℓ and diesel fuel at 3800 riels/ℓ. Compared to the same month in 2006, gasoline was up by 12 percent and diesel by17 percent.

**Phnom Penh: Gasoline & Diesel Prices**
October 2006–December 2007




Sources: CDRI and National Institute of Statistics

នៅខែតុលា អត្រាការប្រាក់ជាមធ្យមចំពោះប្រាក់បញ្ញើជារៀល ក្នុងរយៈ ១២ខែ គឺ ៦,៩៨% រីកើនឡើង ០,៣% ធៀបនឹងខែមុន។ អត្រាការប្រាក់សំរាប់ប្រាក់បញ្ញើជាដុល្លារ ថយចុះ ០,៤% មកត្រឹម ៥,០១%។ អត្រាជាមធ្យមសំរាប់រយៈ១២ខែនេះ គឺពឹងផ្អែកលើរបាយការណ៍ពីធនាគារមួយចំនួនក្នុងចំណោមធនាគារទាំង២៣។

The average interest rate on 12-month bank deposits in riels was 6.98 percent in October, an increase of 0.3 percent compared to the previous month. The rate on dollar deposits decreased by 0.4 percent, to 5.01 percent. This 12-month average rate is based on the number of reporting banks among the 23 banks.

**Interest Rates on 12-Month Bank Deposits**
August 2006–October 2007




Source: NBC's *Economic & Monetary Statistics Review*

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

ប្រាក់រៀលបន្តឡើងថ្លៃទល់នឹងដុល្លារUS ចាប់តាំងពីខែកញ្ញា ២០០៧។ នៅខែធ្នូ ប្រាក់រៀល ប្តូរបាន ៤០០១,៨/ដុល្លារ រឺឡើងថ្លៃ ០,៥% ធៀបនឹងខែមុន។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃបាន ១,៥%។

The riel has continued to appreciate against the US dollar since September 2007. In December, the riel traded at 4001.8 per USD, an appreciation of 0.5 percent from the preceding month. The appreciation from the same month in 2006 was 1.5 percent.

**Riels per US Dollar**
October 2006–December 2007




Sources: National Bank of Cambodia and CDRI

នៅខែធ្នូ ប្រាក់រៀលប្តូរបាន ១៣១,៤រៀល/បាតថៃ រឺធ្លាក់ថ្លៃអស់ ២,៩% ធៀបនឹងខែមុន។ វាប្តូរបាន ២៥,០៤រៀល/១០០ដុងវៀតណាម រឺឡើងថ្លៃ ០,៤%។

The riel traded at 131.4 per Thai baht in December, a depreciation of 2.9 percent compared to the previous month. It exchanged at 25.04 riels per 100 Vietnamese dong, an appreciation of 0.4 percent.

**Riels per THB & VND**
October 2006–December 2007




Source: CDRI

នៅឆ្នាំ២០០៦ ការបើកផ្តល់ពីក្រៅប្រទេសសំរាប់ការអភិវឌ្ឍនៅខេត្តជុំវិញបឹងទន្លេសាបមានចំនួន ៨០,៣លានដុល្លារ។ ក្នុងនោះ ខេត្តសៀមរាបទទួលបានច្រើនជាងគេ គឺ ៤២%។ មូលនិធិនេះត្រូវបានផ្តល់អោយដើម្បីអភិវឌ្ឍវិស័យសង្គមកិច្ច សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ ព្រមទាំង កម្មវិធីពាក់ព័ន្ធនឹងច្រើនវិស័យ។

In 2006, total external development disbursement to provinces around the Tonle Sap lake amounted to USD80.3 m. Of the total, Siem Reap province received the largest amount, 42 percent. The funds were provided to develop the social sector, economy, infrastructure, services and cross-sectoral programmes.

**External Development Disbursement by Provinces around the Tonle Sap Lake**
2006




Source: CDC, Cambodia Aid Effectiveness Report 2007

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

រូបិយវត្ថុទូទៅ M2 កើនតាមអត្រាប្រចាំឆ្នាំបាន ៣,៧% ហើយរូបិយវត្ថុ M1 កើនតាមអត្រាប្រចាំឆ្នាំបាន ២៧% នៅខែតុលា ២០០៧។ ក្នុងរយៈ ១២ខែដល់ខែតុលា M2 កើន ៥២% ធៀបនឹងកំណើន ៥៣% ក្នុងរយៈមួយឆ្នាំដល់ខែកញ្ញា ២០០៧។

Liquidity (M2) grew at an annual rate of 3.7 percent and money (M1) at an annual rate of 27 percent in October 2007. In the previous 12 months, M2 grew by 52 percent, compared to a growth rate of 53 percent in the year to September 2007.

**Monetary Survey**
August 2006–October 2007




Source: National Bank of Cambodia

នៅខែតុលា ឥណទានក្នុងស្រុកកើនតាមអត្រាប្រចាំឆ្នាំបាន ៨៣% និងឥណទានឯកជន កើនតាមអត្រាប្រចាំឆ្នាំបាន ៨៨%។ ក្នុងរយៈ១២ខែដល់ខែតុលា ឥណទានក្នុងស្រុកកើន ៦៣% ធៀបនឹងកំណើន ៦០% ក្នុងរយៈមួយឆ្នាំដល់ខែកញ្ញា ២០០៧។

In October, domestic credit increased at an annualised rate of 83 percent and private sector credit grew at an annualised rate of 88 percent. Over the 12 months to October, domestic credit grew by 63 percent, compared to 60 percent in the year to September 2007.

**Domestic Credit**
August 2006–October 2007




Source: National Bank of Cambodia

នៅខែតុលា ទ្រព្យសកម្មបរទេសសុទ្ធ កើន ០,៧% ធៀបនឹងខែមុន ដល់ ៩៨៣២,២ពាន់លានរៀល។ ឥណទានឯកជន កើន ៥,៤% ដល់ ៥៦៦៧,២ ពាន់លានរៀល ហើយឥណទានរដ្ឋាភិបាលកើន ០,០២% ដល់ ២៩៦,៨ពាន់លានរៀល។ បំណុលធនាគារ កើន ៥,៨% ដល់ ៥៨៥៧,៦ពាន់លានរៀល ក្នុងនោះប្រាក់បញ្ញើរដ្ឋាភិបាលកើន ៥,១% ដល់ ១៩៣៧,៤ពាន់លានរៀល ហើយខ្ទង់ "ផ្សេងៗ" កើន ៦,៣% ដល់ ៣៩២០,២ពាន់លានរៀល។ ប្រតិបត្តិការទាំងនេះ បង្កើនរូបិយវត្ថុទូទៅបាន ០,៣% ដល់ ៩៩៣៨,៥ ពាន់លានរៀល។

In October, net foreign assets increased by 0.7 percent from the previous month to KHR9832.2 bn. Private sector credit rose by 5.4 percent to KHR5667.2 bn and government credit increased by 0.02 percent to KHR296.8 bn. Bank liabilities increased by 5.8 percent to KHR5857.6 bn, of which government deposits rose by 5.1 percent to KHR1937.4 bn and "other" rose by 6.3 percent to KHR3920.2 bn. These operations increased liquidity by 0.3 percent to KHR9938.5 bn.

**Monetary Operations**
August 2006–October 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែកញ្ញា ការនាំចេញសរុបរបស់កម្ពុជា ធ្លាក់ចុះ ២៩% ធៀបនឹងខែមុន មកត្រឹម ២៥២,០លានដុល្លារ។ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះ ៣០% មកត្រឹម ២៣៤,៩លានដុល្លារ ការនាំចេញកៅស៊ូ កើន ៥,៩% ដល់ ៤,១លានដុល្លារ រីឯការនាំចេញត្រី កើន ២៦% ដល់ ០,៥លានដុល្លារ។

Cambodia's total exports decreased by 29 percent from the preceding month to USD252.0 m in September. Garment exports fell by 30 percent to USD234.9 m, while rubber exports increased by 5.9 percent to USD4.1 m and fish exports rose by 26 percent to USD0.5 m.

**Cambodia: Main Exports**
July 2006–September 2007




Source: *Economic & Monetary Statistic, Monthly Bulletin of NBC*

នៅខែកញ្ញា ការនាំចូលបារីកើន ៨៤% ធៀបនឹងខែមុន មកត្រឹម ៤៩,៨ពាន់លានរៀល។ ការនាំចូលស៊ីម៉ង់ត៍ កើន ៣,៣% ដល់ ២០,៨លានរៀល និងការនាំចូលដែក កើន ១០% ដល់ ១១,៧លានរៀល។ ធៀបនឹងខែកញ្ញា ២០០៦ ការនាំចូលបារី កើន ៨,៧% ការនាំចូលស៊ីម៉ង់ត៍ កើន ៥,៨% ហើយការនាំចូលដែក កើន ១៨%។

In September, imports of cigarettes rose by 84 percent from the previous month to KHR49.8 bn. Cement imports rose by 3.3 percent to KHR20.8m, and steel imports increased by 10 percent to KHR11.7 m. Compared to September 2006, cigarette imports rose by 8.7 percent, cement imports by 5.8 percent and steel imports by 18 percent.

**Imports: Cigarettes & Construction Materials**
July 2006–September 2007




Source: NBC's *Economic & Monetary Statistics Review*

នៅខែកញ្ញា ការនាំចូលផលិតផលប្រេងកាត ថយចុះ ១០% ធៀបនឹងខែមុន ដល់ ៨៩,០ពាន់លានរៀល។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចូលប្រេងកាត ថយចុះអស់ ៤,៩%។

Imports of petroleum products decreased by 10 percent from the preceding month to KHR89.0 bn in September. Compared to the same month in 2006, petroleum imports dropped by 4.9 percent.

**Imports: Petroleum Products**
July 2006–September 2007




Source: NBC's *Economic & Monetary Statistics Review*

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកក្កដា ២០០៧ ថវិការចរន្តរបស់រដ្ឋាភិបាលមានអតិរេក ៣៥,៥ពាន់លានរៀល រឺ ៦៧% តិចជាងខែមុន។ ធៀបនឹងខែដូចគ្នាមួយឆ្នាំមុន អតិរេកថយចុះ ២៩%។

The government's current budget surplus in July 2007 was KHR35.5 bn, 67 percent less than in the previous month. Compared to the same month a year earlier, the surplus decreased by 29 percent.

**Current Budget Operations**
February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

នៅខែកក្កដា ២០០៧ ចំណូលថវិការចរន្តសរុបមាន ៣២០,១ពាន់លានរៀល រឺ ធ្លាក់ចុះ ៥,៩% ធៀបនឹងខែមុន។ ចំណូលពន្ធក្នុងស្រុកធ្លាក់ចុះ ១៧% មកត្រឹម ១៧៧,១ពាន់លានរៀល ចំណូលពន្ធនាំចេញ-នាំចូល ធ្លាក់ចុះ ២៦% មកត្រឹម ៦៦,៨ពាន់លានរៀល ចំណូលមិនមែនពន្ធ កើនមួយជាពីរដល់ ៧៦,២ពាន់លានរៀល។

In July 2007, government current revenue totalled KHR320.1 bn, a decline of 5.9 percent from the preceding month. Domestic tax revenue decreased by 17 percent to KHR177.1 bn; revenue from import and export taxes dropped by 26 percent to KHR66.8 bn; revenue from non-tax sources doubled to KHR76.2 bn.

**Current Budget Revenue**
February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

នៅខែកក្កដា ២០០៧ ចំណាយថវិការចរន្តរបស់រដ្ឋាភិបាលកើន ២២% ធៀបនឹងខែមិថុនា ដល់ ២៨៤,៦ពាន់លានរៀល។ ចំណាយលើបៀវត្សរ៍មានចំនួន ១០៦,៨ពាន់លានរៀល រឺកើន ៣៦% រីឯចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម ធ្លាក់ចុះ ១៥% មកត្រឹម ៥៤,៨ពាន់លានរៀល។

Government current budget expenditure increased by 22 percent from June to KHR284.6 bn in July 2007. Wages accounted for KHR106.8 bn, a rise of 36 percent, while spending on subsidies and social assistance fell by 15 percent to KHR54.8 bn.

**Current Budget Expenditure Components**
February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែវិច្ឆិកា ការនាំចេញទំនិញរបស់ US និង តំបន់អឺរ៉ូ កើនឡើង រីឯរបស់ជប៉ុនវិញថយចុះ។ ធៀបនឹងខែមុន ការនាំចេញទំនិញរបស់ US កើន ០,១% ដល់ ១០០,៩៥ពាន់លានដុល្លារ និងការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើន ២,១% ដល់ ១៨៩,៧១ពាន់លានដុល្លារ។ ការនាំចេញទំនិញរបស់ជប៉ុន ធ្លាក់ចុះ ១,២% ធៀបនឹងខែមុន មកត្រឹម ៦៣,៩៤ពាន់លានដុល្លារ។

In November, goods exports of the US and the Euro zone increased, while those of Japan decreased. US goods exports rose by 0.1 percent from the previous month to USD100.95 bn, and goods exports of the Euro zone increased by 2.1 percent to USD189.71 bn. Goods exports of Japan fell by 1.2 percent from the previous month to USD63.94 bn.

**Goods Exports: US, Euro zone & Japan**
November 2006–November 2007




Sources: BEA, Eurostat and OECD

នៅខែវិច្ឆិកា ប្រទេសចិនមានអតិរេកពាណិជ្ជកម្ម ២៦,២៨ពាន់លានដុល្លារ ធៀបនឹងអតិរេក ២៧,០៥ពាន់លានដុល្លារ នៅខែតុលា។ ការនាំចេញសរុប កើន ៩,២% ធៀបនឹងខែមុន ដល់ ១១៧,៦២ពាន់លានដុល្លារ ហើយ ការនាំចូលសរុប កើន ១៣% ដល់ ៩១,៣៤ពាន់លានដុល្លារ។

In November, China recorded a trade surplus of USD26.28 bn, compared to USD27.05 bn in October. Total exports increased by 9.2 percent from the previous month to USD117.62 bn, and total imports rose by 13 percent to USD91.34 bn.

**External Trade: China**
November 2006–November 2007




Sources: National Bureau of Statistics of China

នៅខែវិច្ឆិកា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ៣,១០ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,៧១ពាន់លានដុល្លារ នៅខែតុលា។ ការនាំចេញកើន ០,១% ធៀបនឹងខែមុន ដល់ ១៦,១៣ពាន់លានដុល្លារ រីឯការនាំចូលធ្លាក់ចុះ ២,៨% មកត្រឹម ១៣,០៣ពាន់លានដុល្លារ។

In November, Malaysia recorded a trade surplus of USD3.10 bn, compared to USD2.71 bn in October. Exports rose by 0.1 percent from the previous month to USD16.13, while imports decreased by 2.8 percent to USD13.03 bn.

**External Trade: Malaysia**
November 2006–November 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅ US កើន ៤,៣% ក្នុងរយៈមួយឆ្នាំដល់ខែវិច្ឆិកា ២០០៧។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលជាសំខាន់មកពីការឡើងថ្លៃម្ហូបអាហារ ការថែទាំសុខភាព និង ការដឹកជញ្ជូន។ ក្នុងអំឡុងពេលដដែលអតិផរណាមាន ៣,១% នៅតំបន់អឺរ៉ូ និង ០,៦% នៅជប៉ុន។

US consumer prices rose by 4.3 percent in the year to November 2007. According to the US Department of Labor, this increase largely reflected higher charges for food, medical care and transportation. During the same period, inflation was 3.1 percent in the euro zone and 0.6 percent in Japan.

**Inflation Rates: US, Euro zone & Japan**
(price change from a year earlier)




*Note: The latest data available are for November 2007.*
Sources: IMF and *Economist* (19 January 2008)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ៣,៤% ក្នុងរយៈមួយឆ្នាំដល់ ខែវិច្ឆិកា ២០០៧។ កំណើនថ្លៃម្ហូបអាហារ ការជួលផ្ទះ ខ្សែទស្សនៈកិច្ច និង ប្រេងឥន្ធនៈ បានជំរុញឱ្យថ្លៃទំនិញប្រើប្រាស់កើនឡើង។ ក្នុងអំឡុងពេលដដែល ថ្លៃទំនិញប្រើប្រាស់នៅចិន កើន ៦,៩% និង នៅកូរ៉េខាងត្បូង កើន ៣,៦%។

Hong Kong’s consumer prices rose by 3.4 percent in the year to November 2007. Increases in charges for food, housing rentals, package tours and fuel pushed up the overall price level. During the same period, consumer prices in China and South Korea increased by 6.9 percent and 3.6 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**
(price change from a year earlier)




*Note: The latest data available are for November 2007.*
Sources: IMF and *Economist* (19 January 2008)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ៤,២% ក្នុងរយៈមួយឆ្នាំដល់ខែវិច្ឆិកា ២០០៧។ នាយកដ្ឋានស្ថិតិសិង្ហបុរី សន្មតថាកំណើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការដឹកជញ្ជូននិងទូរគមនាគមន៍ និងការថែទាំសុខភាព។ ក្នុងអំឡុងពេលដដែល អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ មានកំរិត២,៣% នៅម៉ាឡេស៊ី និង ៣,០% នៅថៃ។

Singapore's consumer price index rose by 4.2 percent in the year to November 2007. The Department of Statistics of Singapore attributed this to higher costs for food, transport and communication and health care. During the same period, the year-on-year inflation rate was 2.3 percent in Malaysia and 3.0 percent in Thailand.

**Inflation Rate: Selected ASEAN Countries**
(price change from a year earlier)




*Note: The latest data available are for November 2007.*
Sources: IMF and *Economist* (19 January 2008)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែមករា ២០០៨ ដុល្លារUS ចុះថ្លៃទល់នឹងរូបិយវត្ថុចំបង១ភាគច្រើន។ ទល់នឹងអឺរ៉ូ វាប្តូរបាន ០,៦៨អឺរ៉ូ/ដុល្លារUS រឺធ្លាក់ចុះ ១,១% ធៀបនឹងខែមុន។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១០៧,៩យ៉េន រឺធ្លាក់ចុះ ៤,១ ធៀបនឹងខែធ្នូ ២០០៧។ ដុល្លារUS ធ្លាក់ចុះនៅពេលដែលធនាគារកណ្តាលអាមេរិក បញ្ចុះអត្រាគោលមកត្រឹម ៣% ដើម្បីការពារការធ្លាក់ចុះសេដ្ឋកិច្ច។

In January 2008, the US dollar depreciated against most major currencies. Against the euro, it traded at 0.68 EUR/USD, a 1.1 percent fall from a month earlier. It bought 107.9 Japanese yen, a 4.1 loss from December 2007. The dollar declined as the Federal Reserve lowered its benchmark rate to 3 percent to prevent the economy from falling into recession.

**EUR & JPY per USD**
Jan 07–Jan 08 (monthly average)




Source: Federal Reserve Bank of New York

នៅខែមករា ២០០៨ ប្រាក់វ៉ុនកូរ៉េខាងត្បូង ប្តូរបាន ៩៤១,៩៥វ៉ុន/ដុល្លារ US រឺធ្លាក់ចុះ ១,១% ធៀបនឹងខែធ្នូ។ ក្នុងអំឡុងពេលដដែល ដុល្លារហុងកុងធ្លាក់ថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៨០ដុល្លារហុងកុង/ដុល្លារUS រឺធ្លាក់ចុះ ០,១% ធៀបនឹងខែមុន។ រូបិយវត្ថុអាស៊ីភាគច្រើនធ្លាក់ថ្លៃដោយសារមានការវាយស្មានថា តំរូវការនាំចេញ នឹងធ្លាក់ចុះស្របពេលដែលសេដ្ឋកិច្ចអាមេរិកមានវិបត្តិ។

In January 2008, the South Korean won exchanged at 941.95 per US dollar, a 1.1 percent depreciation from December. During the same period, the Hong Kong dollar also fell slightly against its US counterpart, trading at 7.80 per USD, a 0.1 percent depreciation from a month earlier. Most Asian currencies declined on expectations that demand for exports will wane as the US economy enters a recession.

**KRW & HKD per USD**
Jan 07–Jan 08 (monthly average)




Source: Federal Reserve Bank of New York

នៅខែមករា ២០០៨ ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៤៣១ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹងខែមុនដែលប្តូរបាន ១,៤៤៩ ដុល្លារសិង្ហបុរី/ដុល្លារUS នៅពេលដែលធនាគារកណ្តាលសិង្ហបុរី អាចទប់ទល់នឹងអតិផរណា ហើយអ្នកវិនិយោគបានស្វែងរកចំណេញពីកំណើនសេដ្ឋកិច្ចរបស់រដ្ឋ។ ក្នុងអំឡុងពេលដដែល ប្រាក់បាតថៃធ្លាក់ថ្លៃបន្តិចដោយប្តូរបាន ៣០,២៩បាត/ដុល្លារUS ។

In January, the Singapore dollar appreciated against the US dollar, trading at 1.431 SGD/USD compared to 1.449 SGD/USD a month earlier , as the central bank curbed inflation and investors sought to profit from the city-state's economic growth. During the same period, the Thai baht depreciated slightly, exchanging at 30.29 per US dollar.

**THB & SGD Per USD**
Jan 07–Jan 08 (monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែធ្នូ ថ្លៃអង្ករពិភពលោកឡើងថ្លៃយ៉ាងខ្លាំង ដោយសារកង្វះខាតការផ្គត់ផ្គង់ និងតំរូវការនាំចូលខ្លាំង។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) គឺ ១៦៣,៧ពិន្ទុ ធៀបនឹង ១៥៤,៥ពិន្ទុ នៅខែវិច្ឆិកា។ នៅថៃ ថ្លៃអង្ករថៃ ១00%B កើន ៦,២% ធៀបនឹងខែមុន ដល់ ៣៤២,៨៥ដុល្លារ/តោន។ នៅ US ថ្លៃអង្ករនាំចេញកើន ៥,៧% ដល់ ៤៧៣,៧៥ ដុល្លារ/តោន។

In December, world rice prices increased sharply due to scarce supply and strong import demand. The International Prices Index (IPO) was 163.7, compared to 154.5 in November. In Thailand, the price of Thai 100 percent B rose by 6.2 percent from the previous month to USD342.85 per tonne. In the United States, the export price rose by 5.7 percent to USD473.75 per tonne.

**Rice: International Prices Index & Export Prices**
December 2006–December 2007




Sources: Osiriz/InfoArroz and InterRice.

ថ្លៃជាមធ្យមប្រចាំឆ្នាំរបស់សណ្តែកសៀង និងពោតសំរាប់ឆ្នាំ២00៧ កើនយ៉ាងខ្លាំងធៀបនឹងឆ្នាំ២00៦។ សណ្តែកសៀង លក់ថ្លៃ ២៩៦,៥២ ដុល្លារ/តោន ធៀបនឹង ២១២,៩៩ដុល្លារ/តោន នៅឆ្នាំ២00៦។ ពោតលក់ថ្លៃ ១៤៨,៩៨/តោន កើន ៣៤% ធៀបនឹងឆ្នាំ២00៦។ នៅឆ្នាំ២00៧ ថ្លៃប្រេងឆា កើន ៦៣% ដល់ ៧0៧,៦៩/តោន។

The annual average prices of soybeans and maize for 2007 increased sharply from 2006. Soybeans sold at USD296.52 per tonne, up from USD212.99 in 2006. Maize was USD148.98 per tonne, a 34 percent increase from 2006. The price of palm oil in 2007 increased by 63 percent to USD707.69 per tonne.

**Prices: Soybeans, Maize & Palm Oil**
2004–2007




Source: Food and Agriculture Organisation (FAO)

ថ្លៃប្រេងឆៅ ប្រេងសាំង និងម៉ាស៊ូត ឡើងថ្លៃ នៅរយៈពេលបួនឆ្នាំចុងក្រោយ។ នៅឆ្នាំ២00៧ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៩,២៥ដុល្លារ/ធុង ធៀបនឹង ៦១,៥៩ដុល្លារ/ធុង នៅឆ្នាំ២00៦ និង ៥0,១៣ដុល្លារ/ធុង នៅឆ្នាំ២00៥។ នៅ US Gulf Coast សាំងធម្មតា (អុកតាន ៨៧) ឡើងថ្លៃ ១២% ដល់ ៥៣,៨១សេន/លីត្រ ធៀបនឹងឆ្នាំ២00៦។ ថ្លៃម៉ាសូត (មានលាយស្ពាន់ធ័រតិចលេខ២) គឺ ៥៥,៨៦ សេន/លីត្រ ធៀបនឹង ៥១,២៦ សេន/លីត្រ នៅឆ្នាំ២00៦។

The prices of crude oil, gasoline and diesel oil increased over the last four years. The OPEC spot price of crude oil in 2007 was USD69.25 per barrel, up from USD61.59 in 2006 and USD50.13 in 2005. Regular gasoline (87 octane) prices on the US Gulf Coast rose by 12 percent from 2006 to 53.81 cents per litre. Diesel (low sulphur No.2) on the US Gulf Coast was 55.86 cents per litre, up from 51.26 cents per litre in 2006.

**Prices: Crude Oil, Gasoline & Diesel Fuel**
2004–2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ប្រទេសកម្ពុជាកំពុងមានការរីកដុះដាលខ្លាំងខាងអចលនទ្រព្យ:** ក្រោយមានសង្គ្រាមនិងភាពវឹកវរជាច្រើនទសវត្សរ៍ ប្រទេសកម្ពុជាកំពុងជួបនឹងការរីកដុះដាលខ្លាំងខាងអចលនទ្រព្យ ដែលជំរុញបន្ថែមពីវិនិយោគទុនកូរ៉េខាងត្បូង។ លោក **ស៊ុង បូណា** ប្រធានអចលនទ្រព្យបូណា បាននិយាយថា ថ្លៃដីនៅភ្នំពេញកើនឡើង ពី ៥០ ដល់ ៨០% នៅឆ្នាំ២០០៧ ក្នុងនេះដីសំរាប់លំនៅដ្ឋាននៅភ្នំពេញឡើងថ្លៃក្នុងរយៈមួយឆ្នាំពី ៧០០ដុល្លារ ដល់ ១៦០០ដុល្លារ/ម$^{២}$ នៅឆ្នាំ២០០៧ ដីពាណិជ្ជកម្មឡើងថ្លៃពី ១២០០ដុល្លារ ដល់ ២៥០០ដុល្លា/ម$^{២}$។ លោក សន្និដ្ឋានទៀតថា និន្នាការនេះនឹងបន្តយ៉ាងហោចណាស់រយៈពេលខ្លីដោយសារកត្តាជាច្រើន ដូចជា ស្ថិរភាពនយោបាយ និង ការរីកដុះដាលក្នុងវិស័យទេសចរណ៍។

***Cambodia enjoying real estate boom:*** After decades of war and upheaval, Cambodia is experiencing a real estate boom fuelled by South Korean investment. Sung Bonna, president of Bonna Realty Group, said land prices in Phnom Penh rose by 50 to 80 percent in 2007. Residential land prices in Phnom Penh rose from about $700 to $1600 per square metre in 2007 from the previous year, while commercial land prices rose from $1200 to $2500 per square metre, Sung Bonna said. He predicted that trend will continue, at least in the short term, due to factors including political stability and a tourism boom. (Cited from japantoday.com, 1 February 2008)

**សំលៀកបំពាក់នាំចេញរបស់កម្ពុជាធ្លាក់ចុះ ៤៦% នៅត្រីមាសទី៤:** មន្ត្រីនៃវិស័យឧស្សាហកម្មបាននិយាយថា សំលៀកបំពាក់នាំចេញកម្ពុជា ធ្លាក់ចុះ ៤៦% នៅត្រីមាសទី៤ ឆ្នាំ២០០៧ ដែលជាចុងបញ្ចប់នៃឆ្នាំមួយដ៏អន់បំផុតសំរាប់វិស័យគន្លឹះៗរបស់កម្ពុជា និងបានរំលឹកជាមុនពីលទ្ធភាពបិទទ្វាររោងចក្រ និងការកាត់បន្ថយបុគ្គលិកនៅពេលអនាគត។ លោក **វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានលើកថា ការធ្លាក់ចុះសេដ្ឋកិច្ចនៅ US និង ការបន្តមានទំនាស់ពលកម្មក្នុងស្រុក បានរួមចំណែកដល់ការធ្លាក់ចុះដ៏គំហុកនេះ។ ទោះបីមានការប្រកួតប្រជែងយ៉ាងខ្លាំងក្លានៅក្នុងតំបន់ពីប្រទេសចិន និង វៀតណាមក្តី ក៏កម្ពុជានៅតែដណ្តើមបានអ្នកទិញនៅ US និង អឺរ៉ុប ដោយសារកម្ពុជាមានកេរ្តិ៍ឈ្មោះល្អថា ជួយការពារកំលាំងពលកម្ម។ ចំណុចនេះអាចជួយកម្ពុជា ឱ្យរក្សាបាននូវទីផ្សារមួយចំនួន បើតាមប្រសាសន៍របស់លោក Tuomo Poutiainen ប្រធានទីប្រឹក្សាបច្ចេកទេសក្នុងកម្មវិធីប្រទេសកម្ពុជាសំរាប់ភាពល្អប្រសើរនៃរោងចក្រ របស់អង្គការពលកម្មអន្តរជាតិ ដែលតាមដាន ពីលក្ខខណ្ឌផ្សេងៗនៅទីកន្លែងធ្វើការ។ មន្ត្រីនៃវិស័យឧស្សាហកម្ម បានបញ្ជាក់ទៀតថា នៅទីបំផុតការដាក់កំហិតទប់ទល់នឹងការនាំចេញ វាយនភណ្ឌចិន ដែលនឹងផុតកំណត់នៅឆ្នាំ២០០៩ ក៏ដូចជាផលិតភាព ខ្ពស់ជាង និង ការផ្គត់ផ្គង់សាធារណៈ (ឧ.ទឹកភ្លើង) ថោកជាង នៅវៀតណាម ទំនងជាអាចប៉ះពាល់ដល់ចំណែកទីផ្សាររបស់កម្ពុជាដដែល។

***Fourth quarter Cambodian garment exports plummet 46 percent:*** Cambodian garment exports plummeted 46 percent in the fourth quarter of 2007, capping off a dismal year in the country's key sectors, industry officials say, warning of future factory closures and job cuts. An economic downturn in the United States and continuing domestic labour disputes contributed to the plunge, said Van Sou Ieng, chairperson of the Garment Manufacturers' Association of Cambodia. Despite heavy competition within the region from China and Vietnam, Cambodia has won over buyers in the US and Europe with its labour-friendly image. This should help it to maintain some market presence, said Tuomo Poutiainen, the chief technical adviser with the International Labour Organisation's Better Factories Cambodia programme, which monitors workplace conditions. But the end of US restrictions against Chinese textile exports in 2009, as well as greater productivity and cheaper utilities in Vietnam, are still likely to erode Cambodia's position, industry officials warn. (Cited from afp.google.com 31/01/2008)